ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រឹត្តិបត្រស្ថិតិ
# សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# ប្រចាំត្រីមាសទី២ ឆ្នាំ២០១៩


## អគ្គនាយកដ្ឋានគោលនយោបាយ
## ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ខែសីហា ឆ្នាំ២០១៩

# មាតិកា


I. **សេចក្តីអធិប្បាយសង្ខេប** ........ **១**

II. **ស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ........ **៤**

**១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ** ........ **៤**

**២. សូចនាករតាមវិស័យ** ........ **៥**

២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ........ **៥**

២.៣. អត្រាប្តូរប្រាក់ ........ **៦**

២.៤. ហិរញ្ញវត្ថុសាធារណៈ ........ **៧**

២.៥. ឥណទាន និងរូបិយវត្ថុ ........ **១០**

២.៦. វិស័យពាណិជ្ជកម្ម ........ **១១**

២.៧. ការវិនិយោគឯកជន ........ **១៤**

២.៨. វិស័យទេសចរណ៍ ........ **១៥**

២.៩. វិស័យសំណង់ ........ **១៦**

**៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ** ........ **១៧**

III. **ឧបសម្ព័ន្ធ** ........ **១៩**

# សេចក្តីអធិប្បាយសង្ខេប

ក្នុងបរិការណ៍សេដ្ឋកិច្ចពិភពលោក កំពុងប្រឈមនឹងកំណើនទាប, សង្គ្រាមពាណិជ្ជកម្ម, ការប្រែប្រួលគោលនយោបាយរូបិយវត្ថុ និងនយោបាយភូមិសាស្ត្រនៅហុងកុង, ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈកម្ពុជា ក្នុងត្រីមាសទី២ ឆ្នាំ២០១៩ នៅបន្តភាពរឹងមាំ ដែលបានគាំទ្រដោយកម្រិតប្រែប្រួលទាបនៃអត្រាអតិផរណា និងអត្រាប្តូរប្រាក់រៀលធៀបរូបិយប័ណ្ណអន្តរជាតិ និងអត្រាកំណើនខ្ពស់នៃជន្ទល់សេដ្ឋកិច្ចចម្បងៗ ។ ទន្ទឹមនឹងភាពរឹងមាំនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, កម្ពុជាបានបង្កើននូវទុនបម្រុងរូបិយប័ណ្ណបរទេសសុទ្ធ, ទំហំពាណិជ្ជកម្ម និងចំណូលចរន្ត បានក្នុងកម្រិតខ្ពស់ជាលំដាប់ ។ រីឯទំហំវិនិយោគឯកជន, អ្នកដំណើរទេសចរណ៍ និងគម្រោងសាងសង់ ក៏បានបន្តសន្ទុះកំណើន **ស្របពេលឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធៀបនឹង ផសស បានឈានដល់ ១០៨,៦% (*) ដែលបានឆ្លុះបញ្ចាំងពីតម្រូវការខ្ពស់ផ្នែកឥណទាន សម្រាប់ចូលរួមបន្តជំរុញសកម្មភាពពាណិជ្ជកម្ម និងសេដ្ឋកិច្ច ។**

**ទេសចរណ៍** (1)

នៅត្រីមាសទី២ ឆ្នាំ២០១៩, អ្នកដំណើរមកកម្ពុជា សរុបប្រមាណ ១,៨៦ លាននាក់ បានកើន ១៣,២% ធៀបត្រីមាសដូចគ្នាឆ្នាំ២០១៨ ។ អ្នកដំណើរចិនមកកម្ពុជា បន្តឈរលំដាប់ថ្នាក់លេខមួយ ប្រមាណ ៤១,៧% នៃអ្នកដំណើរសរុប និងមានកំណើនខ្ពស់ប្រមាណ ៧៥,៥% ទោះបីជាចំនួនអ្នកដំណើរចិន បានធ្លាក់ចុះនៅសៀមរាប យ៉ាងណាក្តី ។ **ចំនួនអ្នកដំណើរចិន ក៏សង្កេតឃើញមានបន្តសញ្ញាណធ្លាក់ចុះក្នុងបណ្តាប្រទេសមួយចំនួន ដូចជា ថៃ, វៀតណាម, សិង្ហបុរី, អាមេរិក, កាណាដា, បារាំង និងអ៊ីតាលី ផងដែរ ។**

**សំណង់** (2)

នៅត្រីមាសទី២ ឆ្នាំ២០១៩, សំណើសុំសាងសង់ទូទាំងប្រទេស មានចំនួន ១ ៨៦១ គម្រោង បានកើនពី ១ ២៩០ គម្រោង ក្នុងត្រីមាសដូចគ្នាឆ្នាំ២០១៨ ។ ជាការកត់សម្គាល់ សំណើសុំសាងសង់ មានការរីកលូតលាស់ខ្លាំងក្នុងប្រភេទសំណង់បុរី និងផ្ទះល្វែង ដែលមានតម្លៃជាមធ្យមក្នុងរង្វង់ ៣៣០ ដុល្លារអាមេរិក/ម៉ែត្រការ៉េ ។ ទន្ទឹមនឹងកំណើនសំណើសុំសាងសង់, ការនាំចូលសម្ភារសំណង់ បានបន្តកើនឡើង ៨៣,៧% ។ **ព្រមគ្នានេះ ឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុលើផ្នែកសំណង់ និងអចលនទ្រព្យ ក៏ឃើញមានសន្ទុះកំណើនពី ៣០,៧% ក្នុងត្រីមាសទី២ ឆ្នាំ២០១៨ ទៅ ៣៧,១% ក្នុងត្រីមាសទី២ ឆ្នាំ២០១៩ ។**

---

[1] ប្រភពទិន្នន័យៈ ក្រសួងទេសចរណ៍

[2] ប្រភពទិន្នន័យៈ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

(*) ទិន្នន័យឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជ មានដល់ខែ មិថុនា ឆ្នាំ២០១៩ ។ រីឯទិន្នន័យឥណទានដែលផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺមានត្រឹមខែ ឧសភា ឆ្នាំ២០១៩ ។ ដូច្នេះ ឥណទានដែលផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សម្រាប់ខែមិថុនា គឺជាទិន្នន័យប៉ាន់ស្មាន ។

**ស្ថានភាពហិរញ្ញវត្ថុសាធារណៈ** [3]

យោងតាមទិន្នន័យបឋមពីអគ្គនាយកដ្ឋានរតនាគារជាតិ នៅត្រីមាសទី២ ឆ្នាំ២០១៩ នេះ ការប្រមូលចំណូលចរន្តសរុបនៅរដ្ឋបាលថ្នាក់ជាតិ អនុវត្តបានចំនួន ៦ ២៨៥ ប៊ីលានរៀល ក្នុងនោះ ធៀបនឹងចំណូលចរន្តសរុប, ចំណូលពីពន្ធប្រយោលមាន ៥២,៩%, ពន្ធផ្ទាល់ ២៥,៦%, ពន្ធពាណិជ្ជកម្មក្រៅប្រទេស ១១,៤% និងចំណូលមិនមែនសារពើពន្ធ ១០,១% ។ **ក្នុងន័យនេះ ចំណូលចរន្តសរុបត្រឹមដំណាច់ត្រីមាសទី២ ឆ្នាំ២០១៩ អនុវត្តបាន ៥៧,៩% នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ។**

**អតិផរណា និង អត្រាប្តូរប្រាក់** [4]

អតិផរណាក្នុងត្រីមាសទី២ ឆ្នាំ២០១៩ ស្ថិតនៅកម្រិតទាប ពោលគឺជាមធ្យមក្នុងអត្រា ២,២% ទាបជាងត្រីមាសដូចគ្នាឆ្នាំ២០១៨ ដែលមានអត្រា ២,៤% ដោយសារកំណើនចំណាយទាបនៃក្រុមអាហារ-ភេសជ្ជៈមិនមានជាតិស្រវឹង ២,២% និងការដឹកជញ្ជូន (-០,២%) ។ **រយៈពេលដូចគ្នានេះ, អត្រាប្តូរប្រាក់មានស្ថិរភាពតម្លៃសាច់ប្រាក់ ជាមធ្យម ៤ ០៥២ រៀល/ដុល្លារអាមេរិក ទោះបីជាប្រទេសមួយចំនួន បានកំពុងរងផលប៉ះពាល់ពីការអនុវត្តគោលនយោបាយរូបិយវត្ថុក៏ដោយ ។**

**ប្រតិបត្តិការរូបិយវត្ថុ និងឥណទាន** [5]

អត្រារូបិយវត្ថុទូទៅ ធៀបនឹង ផសស បានឈានដល់ ៨៨,៦% ក្នុងត្រីមាសទី២ ឆ្នាំ២០១៩ ដោយកើនពី ៨០,៣% ក្នុងត្រីមាសទី២ ឆ្នាំ២០១៨ ។ **តម្រូវការឥណទានពីធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានបន្តកើនខ្ពស់ ដែលឆ្លុះបញ្ចាំងដោយអត្រាកំណើនឥណទានប្រមាណ ២៩,៣% ក្នុងត្រីមាសទី២ ឆ្នាំ២០១៩ ដោយកើនពី ២០,៨% ក្នុងត្រីមាសទី២ ឆ្នាំ២០១៨ ។**

**ពាណិជ្ជកម្មក្រៅប្រទេស** [6]

ការនាំចូលទំនិញ ក្នុងត្រីមាសទី២ ឆ្នាំ២០១៩ សម្រេចបាន ២១ ៧៨០ ប៊ីលានរៀល ក្នុងអត្រាកំណើន ១៩,៣% ធៀបឆ្នាំមុន ដោយសារការបន្តកំណើនខ្ពស់លើផលិតផលនាំចូលទំនិញចម្បង ដូចជា ប្រេងឥន្ធនៈ ៩៨,៥%, បរិក្ខារសំណង់ ៨៣,៧% និងទោចក្រយានយន្ត ៥៦,០% ។

ការនាំចេញទំនិញរបស់កម្ពុជា ក្នុងត្រីមាសទី២ ឆ្នាំ២០១៩ មានទំហំ ១៣ ៧០៦ ប៊ីលានរៀល ក្នុងអត្រាកំណើន ១៧% ធៀបឆ្នាំមុន ក្នុងនោះ **ការនាំចេញផលិតផលកាត់ដេរ និងស្បែកជើង បានថមថយកំណើនពី ១៩,៥% ក្នុងត្រីមាសទី២ ឆ្នាំ២០១៨ មកនៅ ១២,៩% ក្នុងត្រីមាសទី២**

[3] ទិន្នន័យបណ្តោះអាសន្នពីអគ្គនាយកដ្ឋានរតនាគារជាតិ ដែលពុំទាន់បានកត់ត្រាទាំងស្រុង ឬបច្ចុប្បន្នភាពទិន្នន័យនៅត្រីមាសក្រោយ។

[4] ប្រភពទិន្នន័យ៖ វិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ និងធនាគារជាតិ នៃកម្ពុជា

[5] ប្រភពទិន្នន័យ៖ ធនាគារជាតិ នៃកម្ពុជា

(*) និយមន័យ៖ ការផ្តល់ឥណទាន ដោយធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សម្រាប់វិស័យសំណង់ និងអចលនទ្រព្យ

[6] ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទិន្នន័យនាំចេញ-នាំចូល នឹងមានការកែសម្រួល

**ឆ្នាំ២០១៩** ខណៈការនាំចេញផលិតផលឧស្សាហកម្មផ្សេងៗទៀត សម្រេចបានកំណើនខ្ពស់ក្នុងអត្រា ១៦,១% ។ **គួសបញ្ជាក់ថា ខណៈការនាំចេញទៅទីផ្សារអឺរ៉ុប បានធ្លាក់ចុះជាអវិជ្ជមានដោយសារការទទួលរងនូវវិធានការការពារ (Safeguard Measures) លើអង្ករ និងការធ្លាក់ចុះនូវការនាំចេញផលិតផលកាត់ដេរ, ស្បែកជើង និងកង់** ។ ផលិតផលនាំចេញទៅទីផ្សារអាមេរិក តាមរយៈប្រព័ន្ធអនុគ្រោះពន្ធគយ (GSP) សម្រេចបានទំហំ ១ ០១០ លានដុល្លារអាមេរិក ក្នុងអត្រាកំណើនខ្ពស់ ៤២,៥% ក្នុងត្រីមាសទី២ ឆ្នាំ២០១៩ ធៀបនឹង ៣៣,០% ក្នុងត្រីមាសទី២ ឆ្នាំ២០១៨ ។

**ការវិនិយោគឯកជន** [7]

ការវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេសដែលអនុម័តដោយ CDC នៅត្រីមាសទី២ ឆ្នាំ២០១៩ មាន ៣៧ គម្រោង លើទុនវិនិយោគ ២ ៦៨៧ លានដុល្លារអាមេរិក ខ្ពស់ជាងរយៈពេលដូចគ្នាឆ្នាំ២០១៨ ដែលមាន ២៩ គម្រោង លើទុនវិនិយោគ ២ ៤២៩ លានដុល្លារអាមេរិក ។ ជាការកត់សម្គាល់នោះ ទុនវិនិយោគប្រមាណ ៧៦,៥% បានមកពីគម្រោងវិនិយោគនៅក្នុងវិស័យសេវាកម្ម និងទេសចរណ៍ ជាពិសេស ការធ្វើពិពិធកម្មទីផ្សារទេសចរណ៍តាមតំបន់ឆ្នេរសមុទ្រ ។ **នៅត្រីមាសទី២ ឆ្នាំ២០១៩ នេះ ការវិនិយោគប្រមាណ ៩២,៧% គឺប្រើប្រាស់ទុនវិនិយោគឯកជនក្នុងស្រុក** ។

[7] ប្រភពទិន្នន័យៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# ស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ

*តារាង 1 ÷ ទិន្នន័យសេដ្ឋកិច្ចសំខាន់ៗ*

| | ឯកតា | ត្រីមាសទី២ | | |
|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ |
| **សូចនាករមូលដ្ឋាន** | | | | |
| ផសស ថ្លៃបច្ចុប្បន្ន -- (ប៉ាន់ស្មានឆ្នាំ២០១៩) | ប៊ីលានរៀល | 89,754 | 98,786 | 108,590 |
| អតិផរណា (កំណើនមធ្យមប្រចាំឆ្នាំ) | % | 3.4% | 2.4% | 2.2% |
| អត្រាប្តូរប្រាក់រៀល/ ដុល្លារ (មធ្យមប្រចាំឆ្នាំ) | រៀល | 4,047 | 4,046 | 4,052 |
| **ឥណទាន និងរូបិយវត្ថុ** | | | | |
| កំណើនរូបិយវត្ថុទូទៅ | % នៃ ផសស | 19.7% | 21.6% | 21.3% |
| អត្រារូបិយវត្ថុទូទៅ | % នៃ ផសស | 72.7% | 80.3% | 88.6% |
| កំណើនឥណទាន | % | 17.9% | 20.8% | 29.3% |
| ទំហំឥណទាន | % នៃ ផសស | 86.3% | 94.7% | 111.4% |
| **ពាណិជ្ជកម្មអន្តរជាតិ** | | | | |
| ទំហំពាណិជ្ជកម្មនាំចេញ | ប៊ីលានរៀល | 10,633 | 12,134 | 13,706 |
| ទំហំពាណិជ្ជកម្មនាំចូល | ប៊ីលានរៀល | (13,857) | (18,259) | (21,780) |
| **វិនិយោគឯកជន** | | | | |
| គម្រោង | ចំនួន | 33 | 29 | 37 |
| ទុនវិនិយោគ | លានដុល្លារ | 1,960 | 2,426 | 2,687 |
| **ទេសចរណ៍** | | | | |
| អ្នកធ្វើដំណើរឆ្លងកាត់ប្រទេសកម្ពុជា | នាក់ | 1,502,896 | 1,711,253 | 1,877,853 |
| **វិស័យសំណង់** | | | | |
| គម្រោង | ចំនួន | 737 | 768 | 1,243 |
| ក្រឡាផ្ទៃ | ពាន់ម២ | 5,212 | 4,166 | 3,469 |
| តម្លៃសាងសង់ | លានដុល្លារ | 3,661 | 1,648 | 1,695 |
| **ថ្លៃទំនិញលើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក)** [8] | | | | |
| អង្ករ | ដុល្លារ/ តោន | 441 | 427 | 420 |
| ប្រេងឆៅ (Brent) -- បារ៉ែល | ដុល្លារ/ បារ៉ែល | 47 | 75 | 63 |
| កៅស៊ូ | ដុល្លារ/ តោន | 1,720 | 1,560 | 1,927 |

ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ, និងធនាគារជាតិ

[8] គឺជាថ្លៃទំនិញចុងត្រីមាស

*រូបភាព 1 ÷ ស្ថានភាពសូចនាករសេដ្ឋកិច្ចសំខាន់ៗ*




ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ, និងធនាគារជាតិ

## ២. សូចនាករតាមវិស័យ

### ២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

*តារាង 2 ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (មធ្យមប្រចាំត្រីមាសទី២)*

| សូចនាករ | ត្រីមាសទី២ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| **មុខទំនិញគ្រប់មុខ** | **167.6** | **170.8** | **175.7** |
| អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | 203.9 | 207.7 | 213.7 |
| ភេសជ្ជៈមានជាតិស្រវឹង និង ថ្នាំជក់ | 158.7 | 159.9 | 167.4 |
| សម្លៀកបំពាក់ និង ស្បែកជើង | 142.5 | 145.1 | 150.0 |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | 124.6 | 124.9 | 126.9 |
| គ្រឿងសង្ហារឹម សម្ភារប្រើប្រាស់ និងការថែទាំ | 149.6 | 150.2 | 151.7 |
| សុខាភិបាល | 132.4 | 133.8 | 136.6 |
| ការដឹកជញ្ជូន | 110.7 | 114.0 | 114.9 |
| គមនាគមន៍ | 68.2 | 67.9 | 67.4 |
| ការកំសាន្ត និងវប្បធម៌ | 118.6 | 118.3 | 118.9 |
| ការសិក្សា | 160.1 | 159.5 | 159.7 |
| ភោជនីយដ្ឋាន | 244.2 | 259.1 | 278.9 |
| ទំនិញ និង សេវាកម្មផ្សេងៗ | 140.0 | 142.0 | 145.6 |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

*រូបភាព 2 ÷ ស្ថានភាពអតិផរណា (មធ្យមប្រចាំត្រីមាស)*




ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

## ២.៣. អត្រាប្តូរប្រាក់

*តារាង 3 ÷ អត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*

| អត្រាប្តូរប្រាក់ចុងខែ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|
| 2011 | 4,043 | 4,045 | 4,095 | 4,065 |
| 2012 | 4,030 | 4,038 | 4,056 | 4,007 |
| 2013 | 3,995 | 4,032 | 4,062 | 4,020 |
| 2014 | 3,994 | 4,026 | 4,060 | 4,070 |
| 2015 | 4,043 | 4,056 | 4,092 | 4,051 |
| 2016 | 4,023 | 4,055 | 4,094 | 4,042 |
| 2017 | 4,016 | 4,047 | 4,080 | 4,037 |
| 2018 | 4,012 | 4,046 | 4,073 | 4,047 |
| 2019 | 4,006 | 4,052 | | |

ប្រភព: ធនាគារជាតិនៃកម្ពុជា

*រូបភាព 3 ÷ ស្ថានភាពអតិផរណា និងអត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាសទី២)*




ប្រភព: ធនាគារជាតិនៃកម្ពុជា

## ២.៤. ហិរញ្ញវត្ថុសាធារណៈ

*តារាង 4 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ផ្នែកចំណូលត្រីមាសទី២*

| ប៊ីលានរៀល | ត្រីមាសទី២ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| **I. ចំណូលក្នុងប្រទេស** | **4,094** | **5,081** | **6,315** |
| **១. ចំណូលចរន្ត** | **4,071** | **5,035** | **6,285** |
| ***ក. ចំណូលសារពើពន្ធ*** | **3,581** | **4,425** | **5,653** |
| **១. ពន្ធផ្ទាល់** | **1,136** | **1,280** | **1,608** |
| ពន្ធលើប្រាក់បៀវត្ស | 101 | 156 | 178 |
| ពន្ធលើប្រាក់ចំណេញ | 973 | 1,123 | 1,430 |
| ពន្ធលើផលទុនដីធ្លី និងផ្ទះសំបែង | 62 | 0 | 0 |
| **២. ពន្ធប្រយោល** | **1,972** | **2,571** | **3,327** |
| ពន្ធលើផលរបរ | 0 | 0 | 0 |
| អាករលើតម្លៃបន្ថែម | 1,120 | 1,371 | 1,674 |
| អាករពិសេស | 829 | 1,172 | 1,617 |
| ចំណូលពន្ធផ្សេងៗទៀត | 22 | 28 | 35 |
| **៣. ពន្ធពាណិជ្ជកម្មក្រៅប្រទេស** | **473** | **575** | **719** |
| ពន្ធនាំចូល | 464 | 566 | 705 |
| ពន្ធនាំចេញ | 9 | 9 | 13 |
| ពន្ធនាំចេញផ្សេងៗទៀត | 0 | 0 | 0 |

| ប៊ីលានរៀល | ត្រីមាសទី២ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| *ខ. ចំណូលមិនមែនសារពើពន្ធ* | **491** | **610** | **632** |
| ចំណូលពីនេសាទ | 0 | 0 | 1 |
| ចំណូលពីព្រៃឈើ | 12 | 6 | 9 |
| ចំណូលពីការជួលសហគ្រាស | 13 | 97 | 5 |
| ចំណូលពីអាកាសចរស៊ីវិល | 41 | 29 | 56 |
| ចំណូលពីសម្បទាន | 125 | 105 | 103 |
| ចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 13 | 15 | 49 |
| អាករស្ថានទូត (ចំណូលពីលិខិតឆ្លងដែន និងទិដ្ឋាការ) | 130 | 0 | 0 |
| ផលពីការបង់សិទ្ធិប្រលង | 3 | 0 | 0 |
| ចំណូលពីការជួល | 5 | 0 | 0 |
| ចំណូលមិនមែនពន្ធផ្សេងៗ | 148 | 357 | 409 |
| **២. ចំណូលមូលធន** | **22** | **45** | **30** |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## *តារាង 5 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ផ្នែកចំណាយត្រីមាសទី២*

| ប៊ីលានរៀល | ត្រីមាសទី២ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| **II. ចំណាយសរុប** | **4,139** | **4,706** | **4,931** |
| **១. ចំណាយចរន្ត** | **2,783** | **3,188** | **3,724** |
| ***ក. ការពារ និងសន្តិសុខជាតិ*** | **525** | **916** | **905** |
| ***ខ. រដ្ឋបាលស៊ីវិល*** | **2,210** | **2,229** | **2,746** |
| ***គ. ចំណាយការប្រាក់*** | **48** | **44** | **74** |
| **២. ចំណាយមូលធន** | **1,356** | **1,518** | **1,207** |
| ហិរញ្ញប្បទានក្នុងស្រុក | 269 | 484 | 414 |
| ពីចំណូលក្នុងស្រុក | (3) | 346 | 414 |
| ពីជំនួយជាទំនិញ | 272 | 139 | 0 |
| ហិរញ្ញប្បទានពីបរទេស | 1,087 | 1,033 | 793 |
| ***និនភាពចរន្ត (សាច់ប្រាក់)*** | **1,088** | **1,847** | **2,561** |
| ***និនភាពទូទៅ (សាច់ប្រាក់)*** | **(247)** | **374** | **1,384** |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## តារាង 6 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ផ្នែកហិរញ្ញប្បទានត្រីមាសទី២

| ប៊ីលានរៀល | ត្រីមាសទី២ | | |
| --- | --- | --- | --- |
| | ២០១៧ | ២០១៨ | ២០១៩ |
| **III. ហិរញ្ញប្បទាន** | **247** | **(374)** | **(1,384)** |
| **១. ហិរញ្ញប្បទានពីបរទេស** | **1,221** | **1,064** | **587** |
| ទ្រទ្រង់ថវិកា | 272 | 139 | 0 |
| ជំនួយគម្រោងអភិវឌ្ឍន៍ | 1,062 | 1,024 | 776 |
| រំលស់បំណុលបរទេស | (113) | (98) | (189) |
| **២. ហិរញ្ញប្បទានក្នុងស្រុក** | **(33)** | **91** | **28** |
| បញ្ញើរដ្ឋាភិបាល | (597) | (490) | (1,470) |
| វិស័យឯកជន | 43 | 0 | 0 |
| ផ្សេងៗ | 520 | 581 | 1,497 |
| **៣. ប្រតិបត្តិការកំពុងដំណើរការ** | **(941)** | **(1,529)** | **(1,999)** |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រូបភាព 4 ÷ ស្ថានភាពតុល្យភាពថវិកាចរន្ត (គិតជាប៊ីលានរៀល) ត្រីមាសទី២




ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៥. ឥណទាន និងរូបិយវត្ថុ

*តារាង 7÷ ស្ថានភាពរូបិយវត្ថុត្រីមាសទី២*

| (ប៊ីលានរៀល) | ត្រីមាសទី២ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **40,285** | **49,422** | **62,700** |
| ទ្រព្យសកម្មបរទេស | 57,241 | 66,736 | 81,660 |
| ទ្រព្យអកម្មបរទេស | (16,955) | (17,314) | (18,960) |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **24,986** | **29,926** | **33,548** |
| ឥណទានក្នុងស្រុក | 51,062 | 59,577 | 72,821 |
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | (10,128) | (12,888) | (18,747) |
| ផ្នែកមិនមែនរដ្ឋាភិបាល | 61,190 | 72,464 | 91,569 |
| **ទ្រព្យសកម្មផ្នែកផ្សេងៗ** | **(26,077)** | **(29,650)** | **(39,273)** |
| ប្រាក់បញ្ញើហាមឃាត់ | (1,495) | (1,811) | (2,249) |
| មូលធន និង ធនបម្រុង | (21,129) | (25,089) | (32,104) |
| ផ្សេងៗ | (3,452) | (2,751) | (4,920) |
| **រូបិយវត្ថុទូទៅ (M2)** | **65,271** | **79,348** | **96,248** |
| រូបិយវត្ថុ (M1) | 8,186 | 9,554 | 11,275 |
| *រូបិយវត្ថុក្រៅធនាគារ* | 7,262 | 8,583 | 10,036 |
| *ប្រាក់បញ្ញើចរន្ត* | 925 | 971 | 1,238 |
| រូបិយវត្ថុផ្សេងៗ | 57,085 | 69,794 | 84,973 |
| *ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ* | 2,240 | 2,690 | 3,336 |
| *ប្រាក់បញ្ញើជារូបិយប័ណ្ណ (បរទេស)* | 54,845 | 67,105 | 81,637 |
| **ទុនបម្រុងរូបិយបណ្ណបរទេសសុទ្ធ (លានដុល្លារ)** | **7,773** | **8,985** | **11,229** |

ប្រភព: ធនាគារជាតិនៃកម្ពុជា

## ២.៦. វិស័យពាណិជ្ជកម្ម

*រូបភាព 5 ៖ បរិក្ខារសំណង់ ទោចក្រ-យានយន្ត និងវាយនភណ្ឌនិងសម្លៀកបំពាក់ (គិតជាប៊ីលានរៀល)*




ប្រភព៖ ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*តារាង 8 ៖ ការនាំចូលតាមមុខទំនិញសំខាន់ៗ (គិតជាប៊ីលានរៀល)*

| មុខទំនិញ | ត្រីមាសទី២ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| ថ្នាំពេទ្យ | 140 | 171 | 201 |
| ភេសជ្ជៈ គ្រឿងស្រវឹង និងបារី | 480 | 560 | 603 |
| ស្ករស និងប៊ីចេង | 54 | 43 | 42 |
| ប្រេងឆា និងអាហារផ្សេងៗ | 356 | 417 | 495 |
| សម្ភារសំណង់ | 626 | 957 | 1,758 |
| អេឡិចត្រូនិច | 6 | 144 | 143 |
| វាយនភណ្ឌ | 4,082 | 5,298 | 5,456 |
| ទោចក្រ-យានយន្ត | 1,166 | 1,383 | 2,157 |
| គ្រឿងបន្លាស់យានយន្ត | 14 | 43 | 33 |
| បរិក្ខារត្រជាក់ | 52 | 128 | 143 |
| មាស | 120 | 338 | 131 |
| ប្រេងឥន្ធនៈ | 838 | 909 | 1,805 |
| ជីកសិកម្ម | 428 | 273 | 242 |
| ផ្សេងៗ | 5,495 | 7,595 | 8,571 |
| **សរុប** | **13,857** | **18,259** | **21,780** |

ប្រភព៖ ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រូបភាព 6÷ ស្ថានភាពមុខទំនិញនាំចេញសំខាន់ៗ (គិតជាប៊ីលានរៀល)




ប្រភព: ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រូបភាព 7÷ ស្ថានភាពនាំចេញទៅទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)




ប្រភព: ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## *តារាង ៩៖ មុខទំនិញនាំចេញ (គិតជាប៊ីលានរៀល)*

| មុខទំនិញ | ត្រីមាសទី២ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| សម្លៀកបំពាក់ | 6,518 | 7,369 | 7,707 |
| ស្បែកជើង | 887 | 1,096 | 1,290 |
| វ៉ាយនភណ្ឌផ្សេងៗ | 192 | 612 | 1,247 |
| គ្រឿងបង្គុំអេឡិចត្រូនិច | 449 | 161 | 347 |
| គ្រឿងបង្គុំរថយន្ត | 31 | 53 | 74 |
| កង់ | 282 | 391 | 315 |
| ឈើមូល | 13 | 147 | 77 |
| ឈើកែច្នៃ | 0 | 0 | 1 |
| ក្តារបន្ទះ | 1 | 19 | 55 |
| ផលិតផលផ្សេងៗពីឈើ | 103 | 5 | 11 |
| អង្ករ | 228 | 291 | 292 |
| កៅស៊ូ | 186 | 148 | 171 |
| ស្ករស | 38 | 99 | 94 |
| ផលិតផលជលផល | 0 | 0 | 0 |
| ផលិតផលកសិកម្មផ្សេងៗ | 44 | 96 | 114 |
| បារី | 21 | 25 | 17 |
| ខ្សែភ្លើង និងបង្គុំខ្សែភ្លើង | 0 | 154 | 155 |
| សំបកកំប៉ុង និងគម្របកំប៉ុង | 0 | 8 | 1 |
| មាស | 0 | 0 | 0 |
| ផលិតផលផ្សេងៗ | 1,636 | 1,459 | 1,739 |
| **នាំចេញសរុប** | **10,633** | **12,134** | **13,706** |

ប្រភព៖ ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៧. ការវិនិយោគឯកជន

*តារាង 10÷ ស្ថិតិវិនិយោគវិស័យឯកជនក្រៅតំបន់សេដ្ឋកិច្ចពិសេស (អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)*

| ការអនុញ្ញាតវិនិយោគដោយ (CDC) | ឯកតា | ត្រីមាសទី២ | | |
|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ |
| គម្រោង | ចំនួន | 33 | 29 | 37 |
| បង្កើតការងារ | ការងារ | 35,626 | 37,479 | 49,242 |
| ទុនវិនិយោគលើវិស័យ | | | | |
| កសិកម្ម | លានដុល្លារ | 61 | 122 | 31 |
| ឧស្សាហកម្ម | លានដុល្លារ | 210 | 128 | 137 |
| សេវាកម្ម | លានដុល្លារ | 1,045 | 2,050 | 461 |
| ទេសចរណ៍ | លានដុល្លារ | 644 | 126 | 2,057 |
| **សរុប** | **លានដុល្លារ** | **1,960** | **2,426** | **2,687** |
| ទុនវិនិយោគក្នុងស្រុក | លានដុល្លារ | 544 | 336 | 2,492 |
| ទុនវិនិយោគបរទេស | លានដុល្លារ | 1,416 | 2,090 | 195 |

ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

*រូបភាព 8÷ ចំនួនគម្រោង និងទុនវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស (គិតជាលានដុល្លារអាមេរិក)*




ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ២.៨. វិស័យទេសចរណ៍

*តារាង 11 ÷ ចំនួនអ្នកដំណើរឆ្លងកាត់ប្រទេសកម្ពុជា*

| សូចនាករ | ត្រីមាសទី២ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| **សរុប** | **1,159,783** | **1,290,407** | **1,460,621** |
| តាមផ្លូវអាកាស | 684,254 | 846,491 | 1,054,825 |
| ភ្នំពេញ | 320,926 | 432,327 | 500,251 |
| សៀមរាប | 351,907 | 375,060 | 367,474 |
| កងកេង | 11,421 | 39,104 | 187,100 |
| តាមផ្លូវគោក និងផ្លូវទឹក | 475,529 | 443,916 | 405,796 |
| ផ្លូវគោក | 457,529 | 420,593 | 385,306 |
| ផ្លូវទឹក | 18,000 | 23,323 | 20,490 |

ប្រភព: ក្រសួងទេសចរណ៍

*រូបភាព 9 ÷ កំណើនអ្នកដំណើរឆ្លងកាត់ប្រទេសកម្ពុជា (គិតជា %)*




ប្រភព: ក្រសួងទេសចរណ៍

## ២.៩. វិស័យសំណង់

*តារាង 12 ÷ គម្រោងអនុញ្ញាតសាងសង់*

| | ឯកត្តា | ត្រីមាសទី២ | | |
|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ |
| **សំណើសុំសាងសង់** | | | | |
| គម្រោង | ចំនួន | 737 | 768 | 1,243 |
| តម្លៃសាងសង់ | លានដុល្លារ | 3,661 | 1,648 | 1,695 |
| **សំណើសុំសាងសង់តាមប្រភេទ** | | | | |
| សំណង់សាធារណៈ | ម៉ែ² | 9,196 | 121,861 | 18,628 |
| លំនៅដ្ឋាន និងភូមិគ្រឹះ | ម៉ែ² | 2,558,229 | 1,664,014 | 1,179,644 |
| សំណង់ឧស្សាហកម្ម | ម៉ែ² | 78,021 | 128,089 | 710,633 |
| សំណង់ពាណិជ្ជកម្ម | ម៉ែ² | 2,426,131 | 205,301 | 941,005 |
| សំណង់ទេសចរណ៍ | ម៉ែ² | 139,949 | 2,046,408 | 348,065 |
| សំណង់វិនិយោគផ្សេងៗ | ម៉ែ² | 110 | 0 | 480 |
| **សរុប** | **ម៉ែ²** | **5,211,635** | **4,165,672** | **3,198,455** |

ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

*រូបភាព 10 ÷ សំណើសុំសាងសង់ គិតជាក្រឡាផ្ទៃ ចែកតាមប្រភេទសំណង់*




ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

*តារាង 13 ÷ ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក)*

| មុខទំនិញ | ឯកតា | ទីផ្សារ | ត្រីមាសទី២ | | |
|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ |
| អង្ករ | តោន/ ដុល្លារ | បាងកក | 441 | 427 | 420 |
| ប្រេងឆៅ Brent | ធុង/ ដុល្លារ | ក្រុងឡុងដ៍ | 47 | 75 | 63 |
| កៅស៊ូ | តោន/ ដុល្លារ | សិង្ហបុរី | 1,720 | 1,560 | 1,927 |
| មាស | អោន/ ដុល្លារ | ហុងកុង | 1,383 | 1,406 | 1,491 |
| ពោតក្រហម | តោន/ ដុល្លារ | ស៊ីកាហ្គោ | 158 | 165 | 195 |
| សណ្តែកសៀង | តោន/ ដុល្លារ | ស៊ីកាហ្គោ | 380 | 413 | 360 |
| ប្រេងដូង | តោន/ ដុល្លារ | រ៉ុតធើដាំ | 1,697 | 934 | 636 |
| ស្ករស | តោន/ ដុល្លារ | ក្រុងឡុងដ៍ | 370 | 381 | 369 |

ប្រភព: គេហទំព័រធនាគារពិភពលោក

*រូបភាព 11 ÷ ថ្លៃជីកសិកម្មលើទីផ្សារអន្តរជាតិសម្រាប់ត្រីមាសទី២ (គិតជាដុល្លារអាមេរិក/ម៉ែត្រទ្រីកតោន)*




ប្រភព: គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

*តារាង 14÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ឆ្នាំគោល ២០១០=១០០)*

| មុខទំនិញ | ត្រីមាសទី២ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| ប្រេងឥន្ធនៈ | 46 | 72 | 60 |
| ផលិតផលកសិកម្ម | 88 | 89 | 85 |
| ម្ហូបអាហារ | 92 | 93 | 88 |
| ឈើ | 85 | 88 | 85 |
| ជីគីមី | 68 | 78 | 87 |

ប្រភពៈ គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

*តារាង 15÷ អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិធៀបនឹងដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*

| រូបិយប័ណ្ណ | ត្រីមាសទី២ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| ជប៉ុន (យ៉េន) | 112.34 | 110.67 | 107.85 |
| ហុងកុង (ដុល្លារ) | 7.80 | 7.85 | 7.81 |
| សិង្ហបុរី (ដុល្លារ) | 1.38 | 1.36 | 1.35 |
| ម៉ាឡេស៊ី (រីងហ្គីត) | 4.29 | 4.04 | 4.13 |
| ហ្វីលីពីន (ប៉េសូ) | 50.50 | 53.35 | 51.20 |
| ថៃ (បាត) | 33.92 | 33.04 | 30.54 |
| ឥណ្ឌូនេស៊ី (រូពា្យ) | 13,297.70 | 14,302.60 | 14,115.80 |
| កូរ៉េ (វ៉ុន) | 1,142.06 | 1,113.97 | 1,155.94 |
| តៃវ៉ាន់ (ដុល្លារ) | 30.40 | 30.46 | 30.99 |
| ចិន (រ៉េនមីនប៊ី) | 6.78 | 6.62 | 6.87 |
| ឡាវ (គីប) | 4,025.65 | 4,033.72 | 4,034.35 |
| វៀតណាម (ដុង) | 8,100.05 | 8,361.94 | 8,572.85 |
| ឥណ្ឌា (រូពី) | 22,446.90 | 22,877.50 | 23,280.00 |
| រុស្ស៊ី (រូប) | 64.55 | 68.44 | 68.83 |
| អូស្ត្រាលី (ដុល្លារ) | 59.22 | 62.75 | 63.21 |
| អង់គ្លេស (ផោន) | 1.30 | 1.35 | 1.42 |
| អឺរ៉ុប (អឺរ៉ូ) | 0.77 | 0.76 | 0.79 |

ប្រភពៈ OANDA (Internet)

# ឧបសម្ព័ន្ធ

*តារាង 16 ÷ ស្ថិតិកសិកម្ម*

| ផលិតកម្មកសិកម្ម និងនាំចេញ | ឯកតា | ត្រីមាសទី២ | | |
|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ |
| **ផ្ទៃដីដាំដុះ** | | | | |
| ស្រូវ | ហិកតា | 1,260,282 | 1,494,695 | 1,283,962 |
| ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម | ហិកតា | 689,660 | 729,402 | 600,069 |
| កៅស៊ូ | ហិកតា | 433,827 | 436,812 | 434,013 |
| **ផ្ទៃដីប្រមូលផល** | | | | |
| ស្រូវ | ហិកតា | na | na | na |
| កៅស៊ូ | ហិកតា | 172,684 | 173,017 | 233,212 |
| **បរិមាណផល** | | | | |
| ស្រូវ | តោន | na | na | na |
| កៅស៊ូ (ក្រែប) | តោន | 92,379 | 84,418 | 105,535 |
| ជលផល | តោន | 301,673 | 319,058 | 338,596 |
| **នាំចេញ** | | | | |
| អង្ករ (*) | តោន | 264,945 | 274,280 | 264,494 |
| កៅស៊ូ | តោន | 63,045 | 61,623 | 63,824 |
| ស្ករ | តោន | 77,579 | 196,581 | 175,672 |
| ផលិតផលជលផល | តោន | 113 | 1,664 | 190 |
| ផលិតផលកសិកម្មផ្សេងៗ | តោន | 158,625 | 130,285 | 89,521 |

ប្រភព: របាយការណ៍ប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
របាយការណ៍ពាណិជ្ជកម្មប្រចាំខែ

*សម្គាល់÷ ស្ថិតិនាំចេញពី (*)អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។ ប៉ុន្តែស្ថិតិនៃការនាំចេញអង្ករពីកម្ពុជាទៅទីផ្សារអន្តរជាតិ កត់ត្រាតាមរយៈលេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ គិតត្រឹមឆមាសទី១ ឆ្នាំ២០១៩ មានរហូតដល់ ២៨១ ៥៣៨ តោន ។*

*រៀបចំដោយនាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច នៃអគ្គនាយកដ្ឋានគោលនយោបាយ*

*ទំនាក់ទំនង:*

*Email: sead@mef.gov.kh*